អគ្គនាយកដ្ឋានពន្ធដារ

GENERAL DEPARTMENT OF TAXATION

សៀវភៅណែនាំ ស្តីពី

# ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ

សម្រាប់មន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធ

មាតិកា

# មាតិកា

**បរិយាយ** **ទំព័រ**


**អារម្ភកថា** ........ iii

**សេចក្តីផ្តើម** ........ ១

**ទស្សនវិស័យ បេសកកម្ម និងក្រមតម្លៃ របស់អគ្គនាយកដ្ឋានពន្ធដារ** ........ ២

**ជំពូកទី១: ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ** ........ ៣

១. សាវតារ ........ ៣

២. បទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ........ ៤

៣. ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ........ ៥

**ជំពូកទី២: វិសាលភាព បែបបទនិងនីតិវិធីនៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ទណ្ឌកម្មព្រហ្មទណ្ឌតាមបទប្បញ្ញត្តិស្តីពីសារពើពន្ធ** ........ ៦

១. វិសាលភាពនៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ........ ៦

២. បែបបទនិងនីតិវិធីនៃការអនុវត្តការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ........ ៦

២.១ មុនពេលបើកការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ...៦

២.២ អំឡុងពេលធ្វើការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ . ៧

២.៣ ក្រោយពេលស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ........ ៩

៣. ទណ្ឌកម្មព្រហ្មទណ្ឌតាមបទប្បញ្ញត្តិស្តីពីសារពើពន្ធ ........ ១០

**ជំពូកទី៣: សិទ្ធិ អំណាច និងកាតព្វកិច្ច សមត្ថកិច្ចនិងនីតិសម្បទា របស់រដ្ឋបាលសារពើពន្ធ** ........ ១១

១. សិទ្ធិទទួលព័ត៌មានរបស់រដ្ឋបាលសារពើពន្ធ ........ ១១

២. អំណាចរបស់រដ្ឋបាលសារពើពន្ធ ........ ១១

៣. សមត្ថកិច្ចរបស់រដ្ឋបាលសារពើពន្ធក្នុងការកសាងសំណុំរឿងព្រហ្មទណ្ឌ ........ ១២

៤. នីតិសម្បទាជានគរបាលយុត្តិធម៌របស់មន្ត្រីពន្ធដារ ........ ១២

**ជំពូកទី៤: សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ** ........ ១៣

១. សិទ្ធិរបស់អ្នកជាប់ពន្ធ ........ ១៣

២. កាតព្វកិច្ចរបស់អ្នកជាប់ពន្ធ ........ ១៣

៣. ការទទួលខុសត្រូវរបស់អភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករ ........ ១៤

**ជំពូកទី៥: ក្រមសីលធម៌ វិន័យ និងវិជ្ជាជីវៈ** ..................... ១៥
១. មន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ..................... ១៥
២. អ្នកជាប់ពន្ធ ឬតំណាងអ្នកជាប់ពន្ធ ..................... ១៧
**ជំពូកទី៦: យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ** ..................... ១៨
**ជំពូកទី៧: យន្តការរាយការណ៍ និងប្តឹង** ..................... ១៩
**ឧបសម្ព័ន្ធ**
ឧបសម្ព័ន្ធទី១៖ សេចក្តីជូនដំណឹងស្តីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ..................... ២១
ឧបសម្ព័ន្ធទី២៖ លិខិតបញ្ជាបេសកកម្ម ..................... ២២
ឧបសម្ព័ន្ធទី៣៖ លិខិតកោះហៅ ..................... ២៣
ឧបសម្ព័ន្ធទី៤៖ លិខិតជូនដំណឹងស្តីពីលទ្ធផលនៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ..................... ២៤

# អារម្ភកថា

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទទួលបន្ទុកគ្រប់គ្រងនិងប្រមូលចំណូលពន្ធផ្ទៃក្នុង ស្របតាមច្បាប់ស្តីពីសារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជាគុណប្រយោជន៍ដល់ថវិកាជាតិ ប្រកបដោយប្រសិទ្ធភាព តម្លាភាព ការទទួលខុសត្រូវ និងវិជ្ជាជីវៈខ្ពស់។ អនុលោមទៅតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ដែលផ្តោតលើការកែទម្រង់និងការពង្រឹងអភិបាលកិច្ចល្អ និងដើម្បីចូលរួមពង្រឹងអភិបាលកិច្ចសាជីវកម្មរបស់វិស័យឯកជន ព្រមទាំងដើម្បីបន្តពង្រឹងសមត្ថភាពការងារគ្រប់គ្រងនិងប្រមូលចំណូលពន្ធរដ្ឋបាលសារពើពន្ធបាននិងកំពុងបន្តរៀបចំនិងបន្តលើកកម្ពស់ភាពស្អាតស្អំរបស់មន្ត្រី ព្រមទាំងបាននិងកំពុងធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងនិងប្រតិបត្តិជាបន្តបន្ទាប់ ជាពិសេសការព្យាយាមវិវត្តន៍ខ្លួនទៅជារដ្ឋបាលសារពើពន្ធទំនើប ស្របតាមឧត្តមានុវត្តន៍តំបន់និងអន្តរជាតិ និងបរិការណ៍សង្គម-សេដ្ឋកិច្ចឌីជីថល អគ្គនាយកដ្ឋានពន្ធដារបានយកចិត្តទុកដាក់កែលម្អសេវាអ្នកជាប់ពន្ធ ដើម្បីលើកកម្ពស់វប្បធម៌បង់ពន្ធនិងពង្រឹងអនុលោមភាពសារពើពន្ធ ដែលនឹងធានាបាននូវចីរភាពចំណូល ក៏ដូចជាចូលរួមចំណែកលើកកម្ពស់ ការប្រកួតប្រជែងដោយស្មើភាពជូនវិស័យឯកជន ស្របតាមយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាល។

ដើម្បីចូលរួមនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ ឆ្នាំ២០២៣-២០២៨ និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ជាពិសេស ដើម្បីចូលរួមគាំទ្រដល់ (១) ចីរភាពកំណើនសេដ្ឋកិច្ច, (២) ចីរភាពកំណើនចំណូល, (៣) ការប្រកួតប្រជែងដោយស្មើភាពនិងយុត្តិធម៌, និង (៤) សមធម៌សង្គម អគ្គនាយកដ្ឋានពន្ធដារ បាននិងកំពុងបន្តជំរុញការអនុវត្តកម្មវិធីកែទម្រង់ស៊ីជម្រៅរដ្ឋបាលសារពើពន្ធដើម្បីបង្កើនប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងតម្លាភាពនៃការប្រមូលចំណូលពន្ធ។ ជាមួយគ្នានេះ អគ្គនាយកដ្ឋានពន្ធដារក៏បានខិតខំកែទម្រង់ទាំងផ្នែកគោលនយោបាយសារពើពន្ធ ក៏ដូចជាផ្នែករដ្ឋបាលសារពើពន្ធ ជាពិសេសការរៀបចំនូវច្បាប់ស្តីពីសារពើពន្ធ និងលិខិតបទដ្ឋានគាំទ្រ ប្រកបដោយសង្គតិភាព និងតម្លាភាព ក្នុងគោលដៅចូលរួមចំណែកកែលម្អបរិយាកាសធុរកិច្ច និងការវិនិយោគលើកកម្ពស់ភាពប្រកួតប្រជែងពង្រឹងតម្លាភាព ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ និងជាពិសេសការចូលរួមធានាបាននូវភាពប្រាកដប្រជាក្នុងការប្រកបអាជីវកម្ម (Predictability) ជូនវិនិយោគិន និងអាជីវករទាំងអស់។

អគ្គនាយកដ្ឋានពន្ធដារក៏បានរៀបចំនូវ **សៀវភៅណែនាំស្តីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ សម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ** ក្នុងគោលបំណងបង្ហាញនិងផ្តល់ជាមធ្យោបាយឱ្យអ្នកជាប់ពន្ធនិងភ្នាក់ងារសេវាកម្មពន្ធដារ ក៏ដូចជាមន្ត្រីពន្ធដារទាំងអស់បានយល់ដឹងអំពីទិដ្ឋភាពទាំងស្រុងនៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។

លើសពីនេះ សៀវភៅណែនាំនេះ គឺជានិយាមនីតិវិធីប្រតិបត្តិការងារ (Standard Operating Procedure - SOP) សម្រាប់អនុវត្តមុខងារនិងភារកិច្ចរបស់មន្ត្រីពន្ធដារ និងជាឯកសារសម្រាប់ឈ្វេងយល់របស់អ្នកជាប់ពន្ធពាក់ព័ន្ធនឹងការងារស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។

កន្លងមក ក្នុងគោលដៅអប់រំ និងផ្សព្វផ្សាយអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវវិធានការ និងយន្តការមួយចំនួនក្នុងការផ្តល់សេវាអ្នកជាប់ពន្ធ ដូចខាងក្រោម៖

- ផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារតាមរយៈគេហទំព័រ និងហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ
- ដាក់ឱ្យអនុវត្តសៀវភៅណែនាំស្តីពីកាតព្វកិច្ច និងសិទ្ធិរបស់អ្នកជាប់ពន្ធ
- បើកវគ្គបណ្តុះបណ្តាលភ្នាក់ងារសេវាកម្មពន្ធដារជាប្រចាំ
- ផ្តល់ការពិគ្រោះយោបល់ជាមួយអ្នកជាប់ពន្ធ តាមរយៈមជ្ឈមណ្ឌលពិគ្រោះយោបល់តាមទូរស័ព្ទ (Call Center), កម្មវិធីជជែកផ្ទាល់តាមសារឆ្លើយឆ្លងជាមួយអ្នកជាប់ពន្ធ (GDT Live Chat) និងបញ្ជរផ្តល់សេវាអ្នកជាប់ពន្ធ
- បង្កើតកម្មវិធីពន្ធដារកម្ពុជា និងកម្មវិធីរៀនអំពីពន្ធដារតាមអនឡាញ ដើម្បីផ្តល់ជាមធ្យោបាយទំនើបទាន់សម័យឱ្យសាធារណជន និងអ្នកជាប់ពន្ធ ធ្វើស្វ័យសិក្សាឈ្វេងយល់បន្ថែមទៀត
- ដោះស្រាយបញ្ហាប្រឈម និងសំណូមពរនានារបស់វិស័យឯកជនក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ តាមរយៈកិច្ចប្រជុំនានា វេទិកាស្តីពីពន្ធដារ និងកម្មវិធីពិគ្រោះយោបល់ផ្សេងៗ
- ជូនដំណឹងដល់សាធារណជន អំពីវិធានការទប់ស្កាត់ការគេចវេះពន្ធនិងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។

តាងនាមអគ្គនាយកដ្ឋានពន្ធដារ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនដល់អ្នកឧកញ៉ា ឧកញ៉ា លោក-លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាសដែលបានចូលរួមបំពេញកាតព្វកិច្ចសារពើពន្ធនាពេលកន្លងមក ដើម្បីជាបុព្វហេតុនៃការកសាងនិងអភិវឌ្ឍន៍ប្រទេសកម្ពុជាឱ្យក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងក្លាយជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ដូចមានកំណត់ ក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា អ្នកឧកញ៉ា ឧកញ៉ា លោក-លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករ

សហគ្រាសទាំងអស់នឹងបន្តចូលរួមសហការជាមួយអគ្គនាយកដ្ឋានពន្ធដារ ដើម្បីបំពេញកាតព្វកិច្ចសារពើពន្ធ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ដែលកិច្ចសហការនេះ គឺជាការចូលរួមចំណែកដ៏ធំធេងក្នុងការឈានទៅសម្រេចគោលនយោបាយ និងយុទ្ធសាស្ត្រចម្បងរបស់រាជរដ្ឋាភិបាលដូចបានលើកឡើងខាងលើ។

ថ្ងៃអង្គារ ១ កើត ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែ មេសា ឆ្នាំ២០២៤

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

# សេចក្តីផ្តើម

សៀវភៅណែនាំស្តីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ត្រូវបានរៀបចំឡើងដើម្បីជានិយាមនីតិវិធីប្រតិបត្តិការងារ (Standard Operating Procedure - SOP) សម្រាប់អនុវត្តមុខងារនិងភារកិច្ចរបស់មន្ត្រីពន្ធដារ និងដើម្បីផ្សព្វផ្សាយជូនអ្នកជាប់ពន្ធនិងសាធារណជនឱ្យបានយល់ដឹងអំពីបែបបទនិងនីតិវិធីនៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។ សៀវភៅណែនាំនេះបរិយាយលម្អិតអំពីមុខងារស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារដែលជាមុខងារដ៏សំខាន់មួយ ក្នុងចំណោមមុខងារចម្បងៗមួយចំនួនទៀតរបស់អគ្គនាយកដ្ឋានពន្ធដារ។ ជាទូទៅ រដ្ឋបាលសារពើពន្ធនានាក្នុងតំបន់ និងពិភពលោក មានមុខងារស៊ើបអង្កេតបទល្មើសពន្ធដារដែលមានតួនាទីស៊ើបអង្កេត និងស្រាវជ្រាវឱ្យឃើញនូវរាល់បទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ និងឈានទៅដល់ការចាត់វិធានការតាមផ្លូវតុលាការ ដើម្បីទប់ស្កាត់និងលុបបំបាត់ការគេចវេះពន្ធនិងអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ដែលធ្វើឱ្យបាត់បង់ធំធេងនូវចំណូលពន្ធដារដែលត្រូវប្រមូលចូលថវិកាជាតិ។

សៀវភៅណែនាំនេះ ផ្តល់ជាមធ្យោបាយឱ្យអ្នកជាប់ពន្ធ សាធារណជន ក៏ដូចជាមន្ត្រីពន្ធដារទាំងអស់បានយល់ជ្រួតជ្រាបប្រកបដោយតម្លាភាពខ្ពស់ អំពីទិដ្ឋភាពទាំងស្រុងនៃមុខងារស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ព្រមទាំងបែបបទនិងនីតិវិធីនៃការអនុវត្តមុខងារនេះដើម្បីជាប្រយោជន៍ជាតិទាំងមូល ដោយសម្រេចបាននូវអនុលោមភាពសារពើពន្ធ ស្របតាមច្បាប់ស្តីពីសារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា។

តាមរយៈសៀវភៅណែនាំនេះ អ្នកជាប់ពន្ធ និងសាធារណជនអាចឈ្វេងយល់អំពីទស្សនវិស័យបេសកកម្ម និងក្រមតម្លៃរបស់អគ្គនាយកដ្ឋានពន្ធដារ វិសាលភាព បែបបទនិងនីតិវិធីនៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ទណ្ឌកម្មនានាតាមច្បាប់ស្តីពីសារពើពន្ធ ក្រមសីលធម៌វិន័យនិងវិជ្ជាជីវៈរបស់មន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ យន្តការរាយការណ៍និងបណ្តឹងតវ៉ា និងយន្តការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្ត។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមយ៉ាងមុតមាំថា សៀវភៅណែនាំនេះនឹងជួយផ្តល់ជាមធ្យោបាយដល់អ្នកជាប់ពន្ធ និងមន្ត្រីពន្ធដារ ឱ្យយល់កាន់តែច្បាស់អំពីបែបបទនិងនីតិវិធីនៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដែលជាចំណែកដ៏ធំដល់ការសម្រេចបាននូវការបំពេញកាតព្វកិច្ចសារពើពន្ធស្របតាមច្បាប់ស្តីពីសារពើពន្ធ។ អគ្គនាយកដ្ឋានពន្ធដារក៏មានសេចក្តីពឹងផងដែរថា អ្នកជាប់ពន្ធនឹងបង្កើនការយល់ដឹងកាន់តែច្បាស់និងស៊ីជម្រៅថែមទៀត អំពីសិទ្ធិនិងកាតព្វកិច្ចក្នុងការចូលរួមសហការជាមួយរដ្ឋបាលសារពើពន្ធឱ្យបានល្អប្រសើរ ក្នុងពេលមន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារអនុវត្តការងារស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។

# ទស្សនវិស័យ បេសកកម្ម និងក្រមតម្លៃ
# របស់អគ្គនាយកដ្ឋានពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារបំពេញភារកិច្ចរបស់ខ្លួនស្របតាមទស្សនវិស័យ បេសកកម្ម និងក្រមតម្លៃ ដូចខាងក្រោម៖

## ទស្សនវិស័យ

ជាអង្គភាពសាធារណៈដែលត្រូវបានជឿជាក់ គោរព និងទទួលស្គាល់លើគុណភាពនិងជំនាញ ក្នុងការប្រមូលចំណូលពន្ធក្នុងស្រុក ដើម្បីចូលរួមអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។

## បេសកកម្ម

ផ្តល់នូវសេវាដែលមានគុណភាព និងពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងសុចរិតភាព ដើម្បីជំរុញអនុលោមភាពដោយស្ម័គ្រចិត្ត។

## ក្រមតម្លៃ

| | | |
|---|---|---|
| ការអនុវត្ត | ៖ | អនុវត្តច្បាប់ គាំទ្រអ្នកជាប់ពន្ធដែលមានអនុលោមភាព តែម៉ឺងម៉ាត់ចំពោះអ្នកជាប់ពន្ធដែលមិនមានអនុលោមភាព |
| វិជ្ជាជីវៈ | ៖ | ប្រើប្រាស់ក្រមសីលធម៌វិជ្ជាជីវៈ និងជំនាញ ដើម្បីផ្តល់នូវសេវាដែលមានភាពសាមញ្ញងាយស្រួល ឆ្លាតវៃនិងនវានុវត្តន៍ |
| ស័ក្តិសិទ្ធិភាព | ៖ | ប្រើប្រាស់ធនធាន ដោយសន្សំសំចៃ ទាន់ពេលវេលា និងចំគោលដៅ |
| សុចរិតភាព | ៖ | ផ្តល់សេវាជូនអ្នកជាប់ពន្ធ ដោយស្មើភាព តម្លាភាព និងស្អាតស្អំ |
| ភាពបត់បែន | ៖ | ឆ្លើយតបយ៉ាងសកម្មទៅនឹងបញ្ហាប្រឈម និងទាញយកប្រយោជន៍ពីគ្រប់ឱកាសដែលមាន។ |

# ជំពូកទី១
# ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារ

## ១. សាវតារ

បច្ចុប្បន្ន ប្រព័ន្ធពន្ធដារនៃព្រះរាជាណាចក្រកម្ពុជាមានរបបពន្ធតែមួយ គឺរបបស្វ័យប្រកាស។ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវបានបែងចែកជាបីប្រភេទគឺ **អ្នកជាប់ពន្ធតូច** **អ្នកជាប់ពន្ធមធ្យម** និង **អ្នកជាប់ពន្ធធំ**។ របបស្វ័យប្រកាសតម្រូវឱ្យអ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារ ធ្វើការគណនាប្រាក់ពន្ធ ដាក់លិខិតប្រកាសសារពើពន្ធ និងបង់ប្រាក់ពន្ធដោយខ្លួនឯងឱ្យបានត្រឹមត្រូវតាមច្បាប់ស្ដីពីសារពើពន្ធ។ ដើម្បីបញ្ជាក់ថាការប្រកាសពន្ធរបស់អ្នកជាប់ពន្ធមានភាពត្រឹមត្រូវ និងដើម្បីពង្រឹងអនុលោមភាពសារពើពន្ធ រដ្ឋបាលសារពើពន្ធមានអំណាចនិងកាតព្វកិច្ច ក្នុងការពិនិត្យ វិភាគ ផ្ទៀងផ្ទាត់ និងកំណត់ពន្ធឡើងវិញ អនុលោមតាមមាត្រា១៩៤ មាត្រា២០៩ និងមាត្រា២១០ នៃច្បាប់ស្ដីពីសារពើពន្ធ។

យោងតាមបទប្បញ្ញត្តិដែលចែងក្នុងផ្នែកទី១ នៃជំពូកទី១៨ នៃច្បាប់ស្ដីពីសារពើពន្ធ ការគេចវេះពន្ធ គឺជាអំពើណាមួយ ដែលបានប្រព្រឹត្តឡើងដោយចេតនា និងរៀបចំទុកជាមុន ដែលនាំឱ្យបាត់ប្រាក់ពន្ធដែលបទប្បញ្ញត្តិស្ដីពីពន្ធដារតម្រូវឱ្យបង់។ ការគេចវេះពន្ធ គឺជាប្រភេទ នៃបទល្មើសមួយ នៃបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារ។ ម្យ៉ាងវិញទៀត សកម្មភាពមួយចំនួន នៃអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្ដីពីពន្ធដារ ក៏ត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារដែរ ហើយសកម្មភាពទាំងពីរខាងលើនេះជាកម្មវត្ថុនៃទណ្ឌកម្មព្រហ្មទណ្ឌតាមច្បាប់ជាធរមាន។

ដើម្បីឱ្យមានតម្លាភាព និងធានាបាននូវការប្រកួតប្រជែងស្មើភាពគ្នា និងដើម្បីបង្កឱ្យមានការជឿទុកចិត្តពីសាធារណជនចំពោះប្រព័ន្ធពន្ធដារ អគ្គនាយកដ្ឋានពន្ធដារមានភារកិច្ច ស៊ើបអង្កេត ស្រាវជ្រាវបទល្មើស និងប្ដឹងចោទប្រកាន់អ្នកប្រព្រឹត្តបទល្មើសទៅតុលាការស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

អគ្គនាយកដ្ឋានពន្ធដារ ត្រូវបានផ្ដល់អំណាចគ្រប់គ្រាន់ក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារ ក្នុងករណីដែលរកឃើញនូវភ័ស្ដុតាង ឬបទល្មើសជាក់ស្ដែងដែលបញ្ជាក់ថាពិតជាមានអំពើគេចវេះពន្ធដោយចេតនា ឬបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារផ្សេងទៀត ដូចមានចែងនៅក្នុងមាត្រាទាំងឡាយនៃច្បាប់ស្ដីពីសារពើពន្ធ។

ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារ គឺជាតួនាទីនិងភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ ដូចមានចែងនៅក្នុងមាត្រា១៩៥ មាត្រា២២៨ មាត្រា២២៩ និងមាត្រា២៣០ នៃច្បាប់ស្ដីពីសារពើពន្ធ, អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ប្រកាសលេខ១២៣២ សហវ.ប្រក ចុះថ្ងៃ ទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានពន្ធដារនិងការកែសម្រួល

ជាបន្តបន្ទាប់ និងប្រកាសលេខ២៧០ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ ២០១៩ ស្តីពីសវនកម្មពន្ធដារ, ប្រកាសលេខ១០២ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ស្តីពីការកែសម្រួលប្រកាសលេខ ១២៣២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋាន ពន្ធដារ ដើម្បីបំពេញបន្ថែមភារកិច្ចនិងរចនាសម្ព័ន្ធឱ្យនាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ។

## ២. បទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ

អនុលោមតាមបទប្បញ្ញត្តិដូចមានចែងក្នុងផ្នែកទី៥ នៃជំពូកទី១៨ នៃច្បាប់ស្តីពីសារពើពន្ធ បទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ រួមមាន៖

១. "ការគេចវេះពន្ធ" (មាត្រា ២២៦នៃច្បាប់ស្តីពីសារពើពន្ធ) គឺជាអំពើណាមួយ ដែលបានប្រព្រឹត្ត ឡើងដោយចេតនា និងរៀបចំទុកជាមុន ដែលនាំឱ្យបាត់ប្រាក់ពន្ធដែលបទប្បញ្ញត្តិស្តីពីពន្ធដារតម្រូវ ឱ្យបង់។ ត្រូវបានចាត់ទុកថាជាការគេចវេះពន្ធផងដែរចំពោះករណីណាមួយដូចខាងក្រោម៖

- ការធ្វេសប្រហែសធ្ងន់ធ្ងរដូចមានចែងក្នុងមាត្រា២២៤ នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវ បានប្រព្រឹត្តឡើងពីរលើកដាច់ពីគ្នាក្នុងរយៈពេល៣(បី)ឆ្នាំនៃឆ្នាំប្រតិទិន។
- ការធ្វេសប្រហែសធ្ងន់ធ្ងរដូចមានចែងក្នុងមាត្រា២២៤ នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវ បានប្រព្រឹត្តឡើងបីលើកឬច្រើនជាងនេះដាច់ពីគ្នាក្នុងរយៈពេល១០(ដប់)ឆ្នាំនៃឆ្នាំប្រតិទិន។

២. "អំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ" មួយចំនួនដែលមានចែងក្នុងមាត្រា២២៥ នៃច្បាប់ស្តីពីសារពើពន្ធ ក្នុងនោះមាន៖

- ព្យាយាមរារាំងការកំណត់និងការប្រមូលពន្ធ
- កសាងឬផ្តល់នូវកំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានក្លែងបន្លំ
- លាក់ទុក ឬបំផ្លាញចោលដោយចេតនានូវបញ្ជិកាគណនេយ្យ កំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានផ្សេងៗ
- ចេញវិក្កយបត្រក្លែងបន្លំ
- មិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធចូលគ្រឹះស្ថានអាជីវកម្មដើម្បីកំណត់និងប្រមូលពន្ធ។

៣. សកម្មភាពមួយចំនួនដែលចែងក្នុងមាត្រា២៤៥ មាត្រា២៤៦ មាត្រា២៤៧ មាត្រា២៤៩ និងមាត្រា២៥០ នៃច្បាប់ស្តីពីសារពើពន្ធ ក្នុងនោះមាន៖

- ប្រកបវិជ្ជាជីវៈជាភ្នាក់ងារសេវាកម្មពន្ធដារដោយគ្មានអាជ្ញាបណ្ណ
- ខកខានមិនបានបង់ប្រាក់ពន្ធដែលបានប្រមូលរួច
- ប្រមូលប្រាក់ពន្ធដែលមិនមានសិទ្ធិប្រមូល។

បទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ត្រូវទទួលរងទណ្ឌកម្មព្រហ្មទណ្ឌតាមបទប្បញ្ញត្តិ ស្តីពីពន្ធដារ។

## ៣. ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារនិងអាជ្ញាយុកាល

ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ គឺជាការស៊ើបអង្កេត និងស្រាវជ្រាវកម្រិតឯកទេសស៊ីជម្រៅ ដើម្បីស្វែងរកឫសគល់ និងភស្តុតាងនៃបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារឱ្យបានច្បាស់លាស់សម្រាប់ជាមូលដ្ឋានក្នុងការទាមទារមកវិញនូវប្រាក់ពន្ធដែលបាត់បង់រួមទាំងពន្ធបន្ថែមនិងការប្រាក់ និងកំណត់អត្តិភាពនៃបទល្មើសដើម្បីប្តឹងចោទប្រកាន់ ព្រមទាំងតម្រូវឱ្យមានការដាក់ទោសចំពោះបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។

អ្នកជាប់ពន្ធត្រូវទទួលរងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារគឺអាស្រ័យតាមហានិភ័យនិងភស្តុតាងច្បាស់លាស់ដែលត្រូវបានរកឃើញ។ យោងតាមមាត្រា១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាយុកាលនៃការប្តឹងចោទប្រកាន់បទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារទៅតុលាការ គឺ ៥ឆ្នាំ ប៉ុន្តែយោងតាមមាត្រា២១០ នៃច្បាប់ស្តីពីសារពើពន្ធ រយៈពេលនៃការកំណត់ពន្ធឡើងវិញ គឺ ១០ឆ្នាំ ប្រសិនបើមានភស្តុតាងបញ្ជាក់ថាមានអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ។ ដូចនេះ អាជ្ញាយុកាលដែលបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ជាកម្មវត្ថុនៃការប្តឹងចោទប្រកាន់អ្នកជាប់ពន្ធទៅតុលាការ គឺ ៥ឆ្នាំ និងជាកម្មវត្ថុនៃការកំណត់ពន្ធឡើងវិញ គឺ ១០ឆ្នាំ ចំពោះករណីប្រព្រឹត្តអំពើរាំងស្ទះ។

# ជំពូកទី២
## វិសាលភាព បែបបទនិងនីតិវិធីនៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ទណ្ឌកម្មព្រហ្មទណ្ឌតាមបទប្បញ្ញត្តិស្តីពីសារពើពន្ធ

### ១. វិសាលភាពនៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ

ក្នុងករណីដែលរកឃើញ ដោយថាហេតុនូវភស្តុតាងដែលបញ្ជាក់ថាពិតជាមានអំពើគេចវេះពន្ធដែលកើតមានឡើងដោយចេតនារៀបចំរបស់អ្នកជាប់ពន្ធ ឬបទល្មើសជាក់ស្តែងដែលអ្នកជាប់ពន្ធបាននិងកំពុងប្រព្រឹត្ត រដ្ឋបាលសារពើពន្ធអាចចុះធ្វើការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារទៅលើអ្នកជាប់ពន្ធ។

អ្នកជាប់ពន្ធដែលទទួលបានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទមាស មិនត្រូវទទួលរងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារទេ ក្នុងអំឡុងពេលវិញ្ញាបនបត្រនោះកំពុងមានសុពលភាព។ ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីរកឃើញថាអ្នកជាប់ពន្ធបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ រដ្ឋបាលសារពើពន្ធអាចចុះស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។

### ២. បែបបទនិងនីតិវិធីនៃការអនុវត្តការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ

#### ២.១ មុនពេលបើកការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ

តាមរយៈនាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ អគ្គនាយកដ្ឋានពន្ធដារធ្វើការប្រមូលព័ត៌មានពីបណ្តាប្រភពពាក់ព័ន្ធនានា ដើម្បីពិនិត្យផ្ទៀងផ្ទាត់និងវិភាគរកកត្តាហានិភ័យទាំងឡាយដែលជាផ្នែកមួយឬទាំងស្រុងនៃការបំពាន ឬការគំរាមកំហែងណាមួយចំពោះប្រព័ន្ធពន្ធដារ។ តាមរយៈលទ្ធផលនៃការវិភាគទាំងនេះ អគ្គនាយកដ្ឋានពន្ធដារអាចឈានទៅដល់ការកំណត់បាននូវតម្រុយ ឬនិន្នាការនៃការគេចវេះពន្ធ ឬវិស័យ និងប្រភេទអ្នកជាប់ពន្ធដែលចាត់ទុកថាមានហានិភ័យខ្ពស់ ឬមានជាប់ទាក់ទិនទៅនឹងការគេចវេះពន្ធ។ នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ ធ្វើការកំណត់ និងជ្រើសរើសសំណុំរឿង ឬករណីដែលមានសូចនាករ ឬតម្រុយច្បាស់លាស់នៃការគេចវេះពន្ធ ឬភស្តុតាងបញ្ជាក់ពីបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារប្រាកដមែន បន្ទាប់មកទើបធ្វើការស្នើសុំគោលការណ៍អនុញ្ញាតដើម្បីបើកការស៊ើបអង្កេតតាមច្បាប់ជាធរមាន។

នៅពេលនាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ ទទួលបានគោលការណ៍អនុញ្ញាតឱ្យបើកការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារលើអ្នកជាប់ពន្ធណាមួយ ប្រសិនបើអ្នកជាប់ពន្ធនោះ កំពុងត្រូវបានធ្វើសវនកម្ម អង្គភាពដែលកំពុងធ្វើសវនកម្មត្រូវបញ្ឈប់ការធ្វើសវនកម្ម ហើយត្រូវបង្វែរករណីអ្នកជាប់ពន្ធទៅនាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារធ្វើការស៊ើបអង្កេត ទៅតាមបែបបទនិងនីតិវិធី ដូចមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ និងជាពិសេសតាមសៀវភៅណែនាំនេះ។ ប្រសិនបើលទ្ធផលនៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ

លើអ្នកជាប់ពន្ធ ដែលត្រូវបានបញ្ជូនដោយអង្គភាពធ្វើសវនកម្ម មិនឈានដល់ការប្ដឹងទៅតុលាការទេ នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ ត្រូវបង្វែរករណីនោះ ទៅអង្គភាពធ្វើសវនកម្មវិញ ដើម្បីបន្តនីតិវិធីសវនកម្ម។ ក៏ដូចគ្នាដែរ នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ ត្រូវបង្វែរគ្រប់ករណីអ្នកជាប់ពន្ធដែលត្រូវបានទទួលរងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារ ដែលមិនឈានដល់ការប្ដឹងទៅតុលាការ ទៅអង្គភាពធ្វើសវនកម្មដើម្បីធ្វើសវនកម្ម តាមបែបបទនិងនីតិវិធីជាធម្មតា។

បែបបទនិងនីតិវិធីនៃការកសាងសំណុំរឿងស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារ ត្រូវធ្វើឡើងតាមជំហានដូចខាងក្រោម៖

ក. ប្រមូលព័ត៌មានពីប្រភពទាំងឡាយដែលទាក់ទិននឹងករណីសង្ស័យ ឬភ័ស្តុតាងពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារ បន្ថែមពីលើព័ត៌មានដែលមានស្រាប់ ដែលក្នុងនោះរួមបញ្ចូលទាំងការប្រមូលព័ត៌មានពីប្រព័ន្ធគ្រប់គ្រងទិន្នន័យអ្នកជាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ។

ខ. ពិនិត្យ វិភាគ ផ្ទៀងផ្ទាត់និងវាយតម្លៃគ្រប់ជ្រុងជ្រោយ ចំពោះព័ត៌មានដែលប្រមូលបានពីប្រភពពាក់ព័ន្ធទាំងឡាយ ដូចមានលើកឡើងក្នុងចំណុច ក ខាងលើ ដើម្បីកំណត់សូចនាករនៃការក្លែងបន្លំ ឬភ័ស្តុតាងបញ្ជាក់ឱ្យបានច្បាស់ថាជាបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារ។

គ. បន្ទាប់ពីពិនិត្យឃើញថា ពិតជាមានសូចនាករ ឬតម្រុយច្បាស់លាស់នៃការក្លែងបន្លំ ឬភ័ស្តុតាង បញ្ជាក់ពីបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារប្រាកដមែន នោះអង្គភាពដែលមានមុខងារ និងភារកិច្ចធ្វើការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារនឹងរៀបចំសំណុំឯកសារ ដើម្បីស្នើសុំកសាងសំណុំរឿងស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារ។

## ២.២. អំឡុងពេលធ្វើការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារ

ក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារ រដ្ឋបាលសារពើពន្ធមានសិទ្ធិចុះឆែកឆេរទីតាំងណាមួយ តាមរយៈដីកាអនុញ្ញាតឱ្យឆែកឆេរ និងមានកិច្ចសហការពីអគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្ថាប័នអនុវត្តន៍ច្បាប់ពាក់ព័ន្ធក្នុងការអនុវត្តដីកាអនុញ្ញាតឱ្យឆែកឆេរ ដើម្បីប្រមូលភ័ស្តុតាង និងចៀសវាងការបំបាត់ភ័ស្តុតាង ដូចមានចែងក្នុងមាត្រា១១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

យោងតាមមាត្រា២៣០ នៃច្បាប់ស្ដីពីសារពើពន្ធ នៅពេលចូលទៅក្នុងគ្រឹះស្ថានអាជីវកម្ម ឬទីកន្លែងដែលត្រូវបានចាត់ទុកថាជាគ្រឹះស្ថានអាជីវកម្ម មន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារមានអំណាចក្នុងការស៊ើបអង្កេតដូចខាងក្រោម៖

១- ចូលទៅក្នុងគ្រឹះស្ថានអាជីវកម្ម ឬទីកន្លែងដែលត្រូវចាត់ទុកថាជាគ្រឹះស្ថានអាជីវកម្មដើម្បីពិនិត្យបញ្ជីគណនេយ្យ លិខិតប្រកាសសារពើពន្ធគ្រប់ប្រភេទ និងឯកសារពាក់ព័ន្ធផ្សេងៗ ដើម្បីកំណត់ពន្ធ។ ការចូលគ្រឹះស្ថានអាជីវកម្មដូចមានចែងក្នុងកថាខណ្ឌនេះ ត្រូវធ្វើឡើងក្នុងម៉ោងអាជីវកម្ម ឬនៅគ្រប់ពេលវេលាដោយអនុវត្តតាមដីការបស់ស្ថាប័នអយ្យការ ឬស្ថាប័នតុលាការ ដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន។

២- នៅពេលដែលបានចូលដោយស្របច្បាប់ទៅក្នុងគ្រឹះស្ថានអាជីវកម្ម ឬទីកន្លែងដែលត្រូវចាត់ទុកថាជាគ្រឹះស្ថានអាជីវកម្មដូចដែលមានចែងក្នុងកថាខណ្ឌទី១នៃមាត្រា២៣០ នៃច្បាប់ស្តីពីសារពើពន្ធ មន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារមានសិទ្ធិ៖

   ក. ធ្វើសម្រង់ ឬចម្លងឯកសារនានា រួមទាំងឯកសារអេឡិចត្រូនិកដែលស្ថិតនៅក្នុងកន្លែងនោះ។

   ខ. ចាប់យកឯកសារនានា ឬវត្ថុតាងដទៃទៀតដែលអាចក្លាយជាព័ត៌មាន ឬភ័ស្តុតាងសម្រាប់កំណត់ប្រាក់ពន្ធដែលត្រូវបង់របស់បុគ្គលណាម្នាក់ ដោយត្រូវធ្វើកំណត់ហេតុស្តីពីការចាប់យក។

   គ. ដាក់ឧបករណ៍សម្រាប់ត្រួតពិនិត្យផ្សេងៗ ឬបោះត្រាបិទសម្គាល់ ឃាត់ទុកទំនិញប្រសិនបើមានជាប់ទាក់ទិនដល់ការអនុវត្តពន្ធណាមួយ។

   ឃ. ធ្វើសារពើភណ្ឌទ្រព្យសកម្ម វត្ថុធាតុដើម ផលិតផលកំពុងផលិត ផលិតផលសម្រេច និងស្តុក/សន្និធិដទៃទៀត។

   ង. ចាប់យក ឃាត់ទុក ឬឃុំគ្រងទ្រព្យសម្បត្តិអ្នកជាប់ពន្ធដើម្បីជានាបំណុលពន្ធ។

   ច. ឃាត់ខ្លួនអ្នកជាប់ពន្ធ ដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដោយអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

៣- ក្នុងគ្រប់ករណីទាំងអស់ នៅពេលមានការរកឃើញបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ នៅក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតរបស់មន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ប្រតិបត្តិការរបស់មន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារទាក់ទិននឹងការប្រមូលភ័ស្តុតាង ការធ្វើកំណត់ហេតុ និងការអនុវត្តរាល់កិច្ចនីតិវិធីព្រហ្មទណ្ឌចាំបាច់ដទៃទៀត ដោយរួមទាំងការឃាត់ខ្លួនជនសង្ស័យផង ត្រូវធ្វើឡើងដោយមន្ត្រីពន្ធដារ ដែលមាននីតិសម្បទាជាមន្ត្រីឬភ្នាក់ងារនគរបាលយុត្តិធម៌ ហើយត្រូវអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

៤- អាចតម្រូវឱ្យស្ថាប័នធនាគារដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ផ្តល់ព័ត៌មានអំពីគណនីរបស់អ្នកជាប់ពន្ធ ឬបុគ្គលពាក់ព័ន្ធនៅធនាគារ ឬឃាត់ទុកគណនីរបស់អ្នកជាប់ពន្ធ ឬបុគ្គលពាក់ព័ន្ធនោះ ក្នុងករណីមានភ័ស្តុតាងបញ្ជាក់ថាបានប្រព្រឹត្តអំពើគេចវេះពន្ធ។

នៅពេលចុះឆែកឆេរដល់ទីតាំង មន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារត្រូវចងក្រងភ័ស្តុតាង កំណត់អត្តិភាពនៃបទល្មើស អ្នកប្រព្រឹត្តបទល្មើស ទំហំនៃការគេចវេះពន្ធ និងអាចសម្ភាស ឬស្តាប់ចម្លើយរបស់អ្នកជាប់ពន្ធ អ្នកគ្រប់គ្រង និងបុគ្គលិកសហគ្រាស ក្រុមគ្រួសាររបស់អ្នកជាប់ពន្ធ និងបុគ្គលពាក់ព័ន្ធផ្សេងទៀត ដូចមានចែងក្នុងមាត្រា១៩៣ មាត្រា១៩៤ និងមាត្រា២០២ នៃច្បាប់ស្តីពីសារពើពន្ធ និងមាត្រា១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

លើសពីនេះ អ្នកជាប់ពន្ធ អ្នកគ្រប់គ្រង បុគ្គលិក ក្រុមគ្រួសាររបស់អ្នកជាប់ពន្ធ តតិយជនផ្សេងទៀត ដែលពាក់ព័ន្ធនឹងករណីបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ អាចត្រូវបានកោះហៅមកស្រាយបំភ្លឺ ឬផ្តល់ចម្លើយពាក់ព័ន្ធនានានៅរដ្ឋបាលសារពើពន្ធ ព្រមទាំងយកមកជាមួយនូវឯកសារពាក់ព័ន្ធមួយចំនួន ផងដែរ ដូចមានចែងក្នុងមាត្រា១៩៣ មាត្រា១៩៤ និងមាត្រា២០២ នៃច្បាប់ស្តីពីសារពើពន្ធ និងមាត្រា១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ អ្នកដែលមានឈ្មោះក្នុងលិខិតកោះហៅ ត្រូវចូលមកដោយផ្ទាល់ ដោយមិនអាច ផ្ទេរសិទ្ធិឱ្យអ្នកដទៃមកជំនួសបានទេ។ ក្នុងករណីមិនចូលខ្លួនតាមការកោះហៅ២ឬ៣ដង ស្ថាប័នអយ្យការ អមសាលាដំបូងអាចនឹងចេញដីកាបញ្ជាឱ្យចូលខ្លួនដូចមានចែងក្នុងមាត្រា១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ក្នុងករណីចាំបាច់ ជាពិសេសនៅពេលជនសង្ស័យគេចខ្លួន និង/ឬជនសង្ស័យអាចគេចខ្លួន ឬបំផ្លាញភស្តុតាង ឬនៅបន្តប្រព្រឹត្តបទល្មើស ឬធ្វើឱ្យរាំងស្ទះ ឬបង្កឧបសគ្គដល់ការស៊ើបអង្កេត ឬ មិនចូលខ្លួនតាមការកោះហៅចំនួន ២ ឬ ៣ដង មន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិ ស្តីពីពន្ធដារ ក្រោមកិច្ចសហការពីអគ្គស្នងការដ្ឋាននគរបាលជាតិ ឬភ្នាក់ងារអនុវត្តន៍ច្បាប់ដទៃទៀត អាចស្នើសុំនិងអនុវត្តដីកាបញ្ជាឱ្យចូលខ្លួនតាមមាត្រា១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីឃាត់ខ្លួន ជនសង្ស័យនោះតាមមាត្រា១១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ នីតិវិធីនៃការឃាត់ខ្លួន ត្រូវអនុវត្តតាម ក្រមនីតិវិធីព្រហ្មទណ្ឌ។

## ២.៣ ក្រោយពេលស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ

យោងតាមមាត្រា១៩៣ និងមាត្រា១៩៤ នៃច្បាប់ស្តីពីសារពើពន្ធ បន្ទាប់ពីបានកំណត់អត្តិភាព បទល្មើស បុគ្គលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ឬករណីគេចវេះពន្ធ និង/ឬអំពើ រាំងស្ទះកម្រិតធ្ងន់ធ្ងរដោយចេតនារបស់អ្នកជាប់ពន្ធរួចហើយ មន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើ បទប្បញ្ញត្តិស្តីពីពន្ធដារនឹងធ្វើការអញ្ជើញអ្នកជាប់ពន្ធនោះមកជួប ដើម្បីពន្យល់បកស្រាយអំពីលទ្ធផលនៃ ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដែលជាអាទិ៍មាន មូលដ្ឋាន និងភស្តុតាង ដែលគាំទ្រដល់ការកំណត់អត្តិភាពបទល្មើស បុគ្គលប្រព្រឹត្តបទល្មើស មូលដ្ឋាននៃការកំណត់ពន្ធ ការកំណត់ពន្ធឡើងវិញ និងការកសាងសំណុំរឿងទៅតុលាការជាដើម។

ប្រសិនបើការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារមិនឈានដល់ការ កសាងសំណុំរឿងទៅតុលាការទេ នោះនាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារនៃអគ្គនាយកដ្ឋាន ពន្ធដារ ត្រូវបង្វែរករណីនោះទៅអង្គភាពពាក់ព័ន្ធដើម្បីបន្តនីតិវិធីសវនកម្មវិញ។

អនុលោមតាមមាត្រា២២៧ នៃច្បាប់ស្តីពីសារពើពន្ធ បណ្តឹងអាជ្ញាចំពោះបទល្មើសព្រហ្មទណ្ឌ លើបទប្បញ្ញត្តិស្តីពីពន្ធដារ ដែលអគ្គនាយកដ្ឋានពន្ធដារបានប្តឹងទៅតុលាការ អាចត្រូវបានរំលត់ តាមរយៈការស្នើសុំសម្របសម្រួលពីសំណាក់អ្នកជាប់ពន្ធ ដោយធ្វើការបង់ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់ ឱ្យគ្រប់ចំនួនតាមការកំណត់។ ក្នុងករណីយល់ព្រម អគ្គនាយកដ្ឋានពន្ធដារត្រូវធ្វើ របាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីពិនិត្យនិងសម្រេច និងត្រូវធ្វើកំណត់ហេតុ ស្តីពីការសម្របសម្រួលជូនស្ថាប័នអយ្យការឬស្ថាប័នតុលាការ។

## ៣. ទណ្ឌកម្មព្រហ្មទណ្ឌតាមបទប្បញ្ញត្តិស្តីពីសារពើពន្ធ

ដោយមិនទាន់គិតដល់ទណ្ឌកម្មរដ្ឋបាល និងទណ្ឌកម្មផ្សេងទៀត៖

៣.១ ទណ្ឌកម្មព្រហ្មទណ្ឌចំពោះរូបវន្តបុគ្គល ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ រួមមាន៖

- ដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៥ (ប្រាំ) ឆ្នាំ
- និងពិន័យជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ដល់ ២០០ ០០០ ០០០ (ពីររយលាន)រៀល ទៅតាមបទល្មើសនីមួយៗ ដូចមានចែងក្នុងមាត្រា២៤២ មាត្រា២៤៣ មាត្រា២៤៥ មាត្រា២៤៦ មាត្រា២៤៧ និងមាត្រា២៥០ នៃច្បាប់ស្តីពីសារពើពន្ធ។

៣.២ យោងតាមមាត្រា២៤៩ នៃច្បាប់ស្តីពីសារពើពន្ធ ការទទួលខុសត្រូវរបស់នីតិបុគ្គលមានដូចខាងក្រោម៖

- ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា២៤២ មាត្រា២៤៣ មាត្រា២៤៥ មាត្រា២៤៦ មាត្រា២៤៧ និងមាត្រា២៥០ នៃច្បាប់ស្តីពីសារពើពន្ធ។
- ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ២០០ ០០០ ០០០ (ពីររយលាន)រៀល ទៅតាមបទល្មើសនីមួយៗ ដូចមានចែងក្នុងមាត្រា២៤២ មាត្រា២៤៣ មាត្រា២៤៦ មាត្រា២៤៧ មាត្រា២៤៥ និងមាត្រា២៥០ នៃច្បាប់ស្តីពីសារពើពន្ធ។
- អាចត្រូវប្រកាសទោសបន្ថែមណាមួយ ឬច្រើនដូចមានចែងក្នុងមាត្រា១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

# ជំពូកទី៣
# សិទ្ធិ អំណាច និងភារកិច្ច សមត្ថកិច្ច និងនីតិសម្បទា របស់រដ្ឋបាលសារពើពន្ធ

## ១. សិទ្ធិទទួលព័ត៌មានរបស់រដ្ឋបាលសារពើពន្ធ

អនុលោមតាមមាត្រា២០២ នៃច្បាប់ស្ដីពីសារពើពន្ធ ក្នុងគោលដៅកំណត់ប្រាក់ពន្ធត្រូវបង់របស់បុគ្គលណាម្នាក់ ឬដើម្បីប្រមូលពន្ធ ឬដើម្បីបំពេញកាតព្វកិច្ចស្របតាមកិច្ចព្រមព្រៀងអន្តរជាតិ រដ្ឋបាលសារពើពន្ធអាចធ្វើលិខិតជូនដំណឹងដល់អ្នកជាប់ពន្ធ ឬតតិយជន រួមទាំងធនាគារ សហគ្រាសធានារ៉ាប់រង និងគ្រឹះស្ថានហិរញ្ញវត្ថុនានាឱ្យ៖

ក. ផ្ដល់ព័ត៌មានដែលទាក់ទិននឹងអ្នកជាប់ពន្ធ ឬបុគ្គលពាក់ព័ន្ធដូចមានចែងក្នុងលិខិតជូនដំណឹង ដូចជាព័ត៌មានស្ដីពី អ្នកផ្គត់ផ្គង់ អតិថិជន ឬគណនីនៅធនាគារ។

ខ. បង្ហាញខ្លួនទៅតាមពេលវេលា និងទីកន្លែងដែលមានបញ្ជាក់នៅក្នុងលិខិតជូនដំណឹង ដើម្បីផ្ដល់ព័ត៌មាន និងដើម្បីបង្ហាញ ឬផ្ដល់ឯកសារឬទិន្នន័យដែលបុគ្គលនោះគ្រប់គ្រងដែលមានបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងលិខិតជូនដំណឹង។

## ២. អំណាចរបស់រដ្ឋបាលសារពើពន្ធ

អនុលោមតាមមាត្រា១៩៤ នៃច្បាប់ស្ដីពីសារពើពន្ធ រដ្ឋបាលសារពើពន្ធមានអំណាចដូចខាងក្រោម៖

ក. កំណត់មូលដ្ឋានគិតពន្ធលើអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ដូចមានចែងក្នុងមាត្រា២០៩ និងមាត្រា២១០ នៃច្បាប់ស្ដីពីសារពើពន្ធ។

ខ. តម្រូវឱ្យអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកបង្ហាញខ្លួនដូចមានចែងក្នុងមាត្រា២០២ នៃច្បាប់ស្ដីពីសារពើពន្ធ។

គ. កំណត់បញ្ជីឯកសារចាំបាច់នានា និងលិខិតយុត្តិការដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវកាន់រក្សាទុក និងផ្ដល់ជូនរដ្ឋបាលសារពើពន្ធ ដូចមានចែងក្នុងមាត្រា២០១ និងមាត្រា២៣០ នៃច្បាប់ស្ដីពីសារពើពន្ធ។

ឃ. ទាមទារឱ្យអ្នកជាប់ពន្ធ ឬតតិយជនផ្ដល់ព័ត៌មានទាក់ទិននឹងអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកដូចមានចែងក្នុងមាត្រា២០២ នៃច្បាប់ស្ដីពីសារពើពន្ធ។

ង. ចូលលំនៅឋាន ឬគ្រឹះស្ថានអាជីវកម្មរបស់អ្នកជាប់ពន្ធ ភ្នាក់ងារកាត់ទុក ឬតតិយជន ដើម្បីទទួលបាននូវព័ត៌មានទាក់ទិននឹងអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ដូចមានចែងក្នុងមាត្រា២៣០ នៃច្បាប់ស្ដីពីសារពើពន្ធ។

ច. ទទួលពីស្ថាប័នរដ្ឋទាំងឡាយនូវព័ត៌មានស្ដីពី ឬដែលទាក់ទិននឹងអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ដូចមានចែងក្នុងមាត្រា២០៩ នៃច្បាប់ស្ដីពីសារពើពន្ធ។

ឆ. អនុវត្តវិធានការតឹងទារចំពោះអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកនៅពេល ដែលបុគ្គលនោះមិនបានបង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម ការប្រាក់ និងការផាកពិន័យជាប្រាក់ តាមការតម្រូវដូចមានចែង ក្នុងមាត្រា២១៧ មាត្រា២១៨ មាត្រា២២០ មាត្រា២២១ និងមាត្រា២២២ នៃច្បាប់ស្តីពីសារពើពន្ធ។

ជ. កំណត់ឡើងវិញនូវប្រតិបត្តិការអាជីវកម្មក្នុងចំណោមបុគ្គលទាក់ទិន ដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ។

ឈ. ច្រានចោលនិង/ឬកំណត់សារជាតុពិតនៃប្រតិបត្តិការទាំងឡាយឡើងវិញ ក្នុងករណីពិនិត្យឃើញថា អ្នកជាប់ពន្ធបានរៀបចំ ឬមានប្រតិបត្តិការទាំងឡាយណាដែលបង្ហាញធនៈមិនពិតឬគ្មានភាពជាក់ស្តែងក្នុងគោលបំណងដើម្បីបន្ថយ ឬបំបាត់ប្រាក់ពន្ធដែលត្រូវបង់ដែលផ្ទុយពីបទប្បញ្ញត្តិស្តីពីពន្ធដារ។

### ៣. សមត្ថកិច្ចរបស់រដ្ឋបាលសារពើពន្ធ ក្នុងការកសាងសំណុំរឿងព្រហ្មទណ្ឌ

អនុលោមតាមមាត្រា ២២៨ នៃច្បាប់ស្តីពីសារពើពន្ធ រដ្ឋបាលសារពើពន្ធជាស្ថាប័នតែមួយគត់ដែលមានសមត្ថកិច្ចក្នុងការស៊ើបអង្កេត និងកសាងសំណុំរឿង ពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដោយអនុវត្តស្របតាមច្បាប់នេះ និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ រដ្ឋបាលសារពើពន្ធ ក៏អាចមានសមត្ថកិច្ចផងដែរ ក្នុងការស៊ើបអង្កេត និងកសាងសំណុំរឿងទាក់ទិននឹងបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ដែលមានការពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ប្រសិនបើមានការអនុញ្ញាតពីព្រះរាជអាជ្ញា។

### ៤. នីតិសម្បទាជានគរបាលយុត្តិធម៌របស់មន្ត្រីពន្ធដារ

អនុលោមតាមមាត្រា ២២៩ នៃច្បាប់ស្តីពីសារពើពន្ធ មន្ត្រីពន្ធដារទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ ឱ្យពិនិត្យបទល្មើសលើបទប្បញ្ញត្តិស្តីពីពន្ធដារ។ រាល់ប្រតិបត្តិការរបស់មន្ត្រីពន្ធដារ ដែលពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ រដ្ឋបាលសារពើពន្ធមានសិទ្ធិស្នើសុំកិច្ចសហការពីស្ថាប័នមានសមត្ថកិច្ច ដើម្បីចូលរួមបង្ក្រាបបទល្មើសលើបទប្បញ្ញត្តិស្តីពីពន្ធដារ។

# ជំពូកទី៤
# សិទ្ធិ និងកាតព្វកិច្ច របស់អ្នកជាប់ពន្ធ

## ១. សិទ្ធិរបស់អ្នកជាប់ពន្ធ

យោងតាមមាត្រា១៩៣ នៃច្បាប់ស្តីពីសារពើពន្ធ អ្នកជាប់ពន្ធមានសិទ្ធិដូចខាងក្រោម៖

ក. ទទួលបាននូវការរក្សាទុកជាការសម្ងាត់ និងត្រូវបានយកមកប្រើប្រាស់តែក្នុងគោលដៅដែលមានបញ្ជាក់នៅក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ នូវព័ត៌មាននានាទាក់ទិននឹងកិច្ចការអាជីវកម្មរបស់ខ្លួនដែលបានផ្តល់ឱ្យរដ្ឋបាលសារពើពន្ធ ដូចមានចែងក្នុងមាត្រា១៩៧ នៃច្បាប់ស្តីពីសារពើពន្ធ។

ខ. ទទួលព័ត៌មានជាប្រចាំអំពីកិច្ចដំណើរការនៃប្រព័ន្ធពន្ធដារ និងនីតិវិធីនៃការកំណត់ពន្ធដូចមានចែងក្នុងមាត្រា១៩៩ និងមាត្រា២១១នៃច្បាប់ស្តីពីសារពើពន្ធ។

គ. ទទួលព័ត៌មានអំពីសិទ្ធិរបស់ខ្លួន រួមទាំងសិទ្ធិក្នុងការប្តឹងតវ៉ាដូចមានចែងក្នុងមាត្រា២១១ និងមាត្រា២៣៨ នៃច្បាប់ស្តីពីសារពើពន្ធ។

ឃ. ប្តឹងតវ៉ាចំពោះរាល់សេចក្តីសម្រេចរបស់រដ្ឋបាលសារពើពន្ធ ដូចមានចែងក្នុងមាត្រា២១១ និងមាត្រា២៣៨ នៃច្បាប់ស្តីពីសារពើពន្ធ។

ង. បង់ពន្ធមិនឱ្យលើសពីបទប្បញ្ញត្តិស្តីពីពន្ធដារកំណត់ ដូចមានចែងក្នុងមាត្រា២១៣ នៃច្បាប់ស្តីពីសារពើពន្ធ។

## ២. កាតព្វកិច្ចរបស់អ្នកជាប់ពន្ធ

យោងតាមមាត្រា១៩៣ នៃច្បាប់ស្តីពីសារពើពន្ធ អ្នកជាប់ពន្ធមានកាតព្វកិច្ចពាក់ព័ន្ធនឹងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចខាងក្រោម៖

ក. ផ្តល់ព័ត៌មានដល់រដ្ឋបាលសារពើពន្ធ តាមការតម្រូវនៃបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចមានចែងក្នុងមាត្រា២០១ និងមាត្រា២០៦ នៃច្បាប់ស្តីពីសារពើពន្ធ។

ខ. កាន់ ថែរក្សា និងត្រូវបង្ហាញបញ្ជី លិខិតយុត្តិការ និងឯកសារផ្សេងៗដល់រដ្ឋបាលសារពើពន្ធដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ និងមាត្រា២០១ នៃច្បាប់ស្តីពីសារពើពន្ធ។

គ. បង្ហាញខ្លួនចំពោះរដ្ឋបាលសារពើពន្ធតាមកាលបរិច្ឆេទដែលមានចុះក្នុងលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធដូចមានចែងក្នុងមាត្រា២០២ នៃច្បាប់ស្តីពីសារពើពន្ធ។

ឃ. បង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗទៀត ដែលរដ្ឋបាលសារពើពន្ធបានកំណត់ទៅតាមកាលបរិច្ឆេទដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ឬដែលរដ្ឋបាលសារពើពន្ធបានជូនដំណឹងជាលាយលក្ខណ៍អក្សរ ដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ និងមាត្រា២១៣ មាត្រា២៣២ និងមាត្រា២៣៣ នៃច្បាប់ស្តីពីសារពើពន្ធ។

### ៣. ការទទួលខុសត្រូវរបស់អភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករ

មាត្រា ២១៤ នៃច្បាប់ស្តីពីសារពើពន្ធ ចែងអំពីការទទួលខុសត្រូវរបស់អភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករ។ ប្រសិនបើអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករ របស់សហគ្រាសណាមួយដឹងឮ ឬមានចេតនាធ្វើឱ្យសហគ្រាសមិនរាយការណ៍ ឬរាយការណ៍បន្ថយនូវប្រាក់ពន្ធដោយរំលោភ ទៅលើបទប្បញ្ញត្តិស្តីពីពន្ធដារ ឬមិនឱ្យបង់ពន្ធកាត់ទុកជូនរដ្ឋបាលសារពើពន្ធ អភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករទាំងនោះ ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះប្រាក់ពន្ធដែលត្រូវបង់។

# ជំពូកទី៥
# ក្រមសីលធម៌ វិន័យ និងវិជ្ជាជីវៈ

## ១. មន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ

មន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារគ្រប់រូប ត្រូវប្រកាន់ខ្ជាប់ខ្លួននូវក្រមសីលធម៌ វិន័យ និងវិជ្ជាជីវៈ ក្នុងពេលបំពេញការងារ ដូចខាងក្រោម៖

### ១.១ សុចរិត និងមិនលំអៀង

ក. ត្រូវប្រកាន់ខ្ជាប់នូវភាពសុចរិត ទៀងត្រង់ មិនលំអៀង និងត្រូវចៀសវាងការរើសអើង និងការប្រកាន់ពូជសាសន៍ចំពោះអ្នកជាប់ពន្ធ។

ខ. ត្រូវអនុវត្តការងារស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាស្តីពីពន្ធដារ។

គ. មិនត្រូវមានការឃុបឃិតជាមួយអ្នកជាប់ពន្ធ ឬបុគ្គលពាក់ព័ន្ធផ្សេងទៀតក្នុងចេតនាគេចវេះ រារាំង និងបន្លំប្រាក់ពន្ធ។

ឃ. មិនត្រូវស្នើសុំ ឬទទួលអំណោយ និងសំណូក ក្នុងទម្រង់ជាប្រាក់ សម្ភារ ទំនិញ ឬការផ្តល់អាទិភាពឬគ្រឿងលើកទឹកចិត្តណាមួយ ទោះដោយផ្ទាល់ឬប្រយោល។

ង. ត្រូវប្រកាន់ជំហរឯករាជ្យ និងមិនត្រូវមានទំនាស់ផលប្រយោជន៍ជាមួយអ្នកជាប់ពន្ធ។

ច. ត្រូវធានាថារាល់របាយការណ៍ និងកំណត់ហេតុការងារពាក់ព័ន្ធមានភាពជាក់លាក់ ច្បាស់លាស់ពិតប្រាកដ ទៀងត្រង់ មិនលំអៀង និងភាពទទួលខុសត្រូវខ្ពស់។

### ១.២ បច្ចេកទេសវិជ្ជាជីវៈ

ក. ត្រូវមានចំណេះដឹងច្បាស់លាស់អំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាស្តីពីពន្ធដារពាក់ព័ន្ធនឹងជំនាញ។

ខ. ត្រូវមានជំនាញវិជ្ជាជីវៈច្បាស់លាស់ក្នុងការបំពេញការងារតាមភារកិច្ច។

គ. ត្រូវវិភាគព័ត៌មានដែលប្រមូលបានពីអ្នកជាប់ពន្ធ និងប្រភពព័ត៌មានផ្សេងៗទៀតឱ្យបានគ្រប់ជ្រុងជ្រោយ។

ឃ. ត្រូវស្តាប់ និងពិចារណាលើការបកស្រាយ ឬការពន្យល់របស់អ្នកជាប់ពន្ធ។

ង. ត្រូវពិនិត្យផ្ទៀងផ្ទាត់ឱ្យបានគ្រប់ជ្រុងជ្រោយនូវឯកសារដែលអ្នកជាប់ពន្ធបានផ្តល់ឱ្យ។

ច. ត្រូវស្លៀកពាក់ឯកសណ្ឋានពន្ធដារ និងប្រើប្រាស់ប័ណ្ណសម្គាល់មន្ត្រីពន្ធដារ។

ឆ. ត្រូវមានលិខិតឧទ្ទេសនាម នៅពេលចុះដល់ទីតាំងអាជីវកម្ម។

ជ. មិនត្រូវពន្យារពេលក្នុងការចេញលិខិតជូនដំណឹងស្តីពីលទ្ធផលនៃការស៊ើបអង្កេតដោយគ្មានហេតុផលសមរម្យ បន្ទាប់ពីអ្នកជាប់ពន្ធបានផ្តល់ឯកសារគ្រប់គ្រាន់តាមការស្នើសុំ។

### ១.៣ អាកប្បកិរិយា និងការប្រាស្រ័យទាក់ទង

ក. ត្រូវមានអាកប្បកិរិយាទន់ភ្លន់ ថ្លៃថ្នូរ តែម៉ឺងម៉ាត់។

ខ. ត្រូវមានភាពរួសរាយរាក់ទាក់ រហ័សរហួន ប្រកបដោយគុណភាពសេវាកម្មវិជ្ជាជីវៈ។

គ. មិនត្រូវប្រមាថ ចំអក សម្លុត គំរាមកំហែង ឬប្រើពាក្យសំដីមិនសមរម្យ។

ឃ. មិនត្រូវរើសអើងភេទ ជាតិសាសន៍ ពណ៌សម្បុរ និងសាសនា។

ង. មិនត្រូវសេពគ្រឿងស្រវឹង គ្រឿងញៀន លេងល្បែងស៊ីសង ឬប្រព្រឹត្តអំពើអសីលធម៌។

ច. មិនត្រូវយកអាវុធ គ្រឿងផ្ទុះ និងវត្ថុធាតុ ឬសារធាតុដែលអាចបង្កគ្រោះថ្នាក់។

### ១.៤ ឯករាជ្យភាព និងទំនាស់ផលប្រយោជន៍

ក. មិនស្ថិតក្រោមសម្ពាធ ឬបញ្ជាពីខាងក្រៅ ទោះបីជាដើម្បីផលប្រយោជន៍ ឬមិនដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ដែលធ្វើឱ្យជះឥទ្ធិពលអវិជ្ជមានដល់ប្រសិទ្ធភាពការងារ។

ខ. មិនត្រូវទទួលយកផលប្រយោជន៍ផ្ទាល់ខ្លួន ដែលធ្វើឱ្យអន់ថយដល់ភាពសុចរិតនិងភាពស្មោះត្រង់ ក្រៅពីអ្វីដែលច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាអនុញ្ញាត។

គ. មិនត្រូវទៅជួយរៀបចំបញ្ជិកាគណនេយ្យឱ្យអ្នកជាប់ពន្ធ។

ឃ. មិនត្រូវប្រើតួនាទីផ្លូវការរបស់ខ្លួនដើម្បីមានឥទ្ធិពល ឬបង្វែរនីតិវិធីរបស់រដ្ឋបាលសារពើពន្ធ សម្រាប់ជាផលប្រយោជន៍របស់ខ្លួនឬគ្រួសារ។

### ១.៥ រក្សាការសម្ងាត់

ក. ត្រូវប្រកាន់ខ្ជាប់នូវការរក្សាការសម្ងាត់នូវព័ត៌មានរបស់អ្នកជាប់ពន្ធ ដែលកំណត់ដោយច្បាប់ស្តីពីសារពើពន្ធ។

ខ. មិនត្រូវប្រើប្រាស់ព័ត៌មានសម្ងាត់របស់អ្នកជាប់ពន្ធ ដែលកំណត់ដោយច្បាប់ស្តីពីសារពើពន្ធ សម្រាប់បម្រើផលប្រយោជន៍ផ្ទាល់ខ្លួន ឬសម្រាប់គោលបំណងមិនផ្លូវការ ឬសម្រាប់គោលបំណងទុច្ចរិតផ្សេងទៀត។

មន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដែលខកខានមិនគោរពតាមគោលការណ៍នៃក្រមសីលធម៌នេះ នឹងត្រូវទទួលរងនូវការដាក់ពិន័យ ឬ/និងទណ្ឌកម្ម ស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល, ច្បាប់ស្តីពីសារពើពន្ធ, សេចក្តីណែនាំស្តីពីវិន័យរបស់មន្ត្រីពន្ធដារ, និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

ក្រមសីលធម៌ វិន័យ និងវិជ្ជាជីវៈរបស់មន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ នឹងត្រូវបានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃតាមយន្តការសវនកម្មផ្ទៃក្នុងរបស់អគ្គនាយកដ្ឋានពន្ធដារ។

## ២. អ្នកជាប់ពន្ធ ឬតំណាងអ្នកជាប់ពន្ធ

ដើម្បីចូលរួមការអនុវត្តបែបបទនិងនីតិវិធីនៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ អ្នកជាប់ពន្ធ ឬតំណាងអ្នកជាប់ពន្ធ ត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌ ដូចខាងក្រោម៖

ក. មិនត្រូវប្រើពាក្យសំដីមិនសមរម្យ ប្រមាថ សម្លុត គំរាមកំហែង និងចំអកឡកឡឺយលើមន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។

ខ. មិនត្រូវប្រើអំពើហិង្សា និងអាកប្បកិរិយាមិនសមរម្យចំពោះមន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។

គ. មិនត្រូវដាក់សម្ពាធ ដោយផ្ទាល់ ឬដោយប្រយោលចំពោះមន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។

ឃ. មិនត្រូវប្រើប្រាស់អាវុធគ្រប់ប្រភេទដើម្បីបន្លាច ឬគំរាម ក្នុងពេលជួបជាមួយមន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។

ង. មិនត្រូវរារាំងមន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ក្នុងការចុះបំពេញការងារ និងចូលទៅទីតាំងរបស់អ្នកជាប់ពន្ធស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន។

ច. មិនត្រូវផ្តល់អំណោយ ឬសំណូក ដោយផ្ទាល់ ឬដោយប្រយោលដល់មន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។

ឆ. មិនត្រូវព្យាយាមពន្យារពេលដោយចេតនាក្នុងការផ្តល់ឯកសារពាក់ព័ន្ធចាំបាច់ ដែលតម្រូវដោយមន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។

ជ. មិនត្រូវឃុបឃិតជាមួយមន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ក្នុងការរៀបចំបញ្ជិកាគណនេយ្យ ក្នុងចេតនាគេចវេះពន្ធ និង/ឬរាំងស្ទះចំពោះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ឬចៀសវាងការបង់ពន្ធ។

ឈ. មិនត្រូវថតសំឡេង រូបភាព ឬវីឌីអូ មន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដោយគ្មានការអនុញ្ញាតពីមន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។

# ជំពូកទី៦
# យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

គណៈកម្មការគ្រប់គ្រងការអនុវត្តការងារសវនកម្មពន្ធដារ និងស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ ត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តបែបបទនិងនីតិវិធីនៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ តាមស្មារតីនៃសៀវភៅណែនាំនេះ។

# ជំពូកទី៧

# យន្តការរាយការណ៍ និងប្ដឹង

ក្នុងករណីអ្នកជាប់ពន្ធមានភ័ស្តុតាង ឬរកឃើញថា មន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ បានប្រព្រឹត្តខុសពីក្រមសីលធម៌ វិន័យ និងវិជ្ជាជីវៈដូចមានចែងខាងលើ អ្នកជាប់ពន្ធអាចរាយការណ៍ ឬប្តឹងទៅ៖

១- គណៈកម្មការគ្រប់គ្រងការអនុវត្តការងារសវនកម្មពន្ធដារ និងស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ តាមរយៈ៖

- **លេខ Hot Line** ៖ ១២៧៧ (Extension ២៤០០)
- **សារអេឡិចត្រូនិក** ៖ gdt@tax.gov.kh និង dlpic@tax.gov.kh
- **បញ្ជរទទួលលិខិត** ៖ បញ្ជរទទួលពាក្យបណ្តឹងជាន់ទី២ នៃអគ្គនាយកដ្ឋានពន្ធដារ អគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

២- អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈ៖

- **លេខទំនាក់ទំនង** ៖ ០៩៣ ៥៤៧ ៩៨១, ០៨៦ ៧០៤ ២០២
- **សារអេឡិចត្រូនិក** ៖ gdiamef@gmail.com
- **អាសយដ្ឋាន** ៖ ផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

៣- គណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈ៖

- **លេខទំនាក់ទំនង** ៖ ០២៣ ៨៩០ ៦៦៦
- **សារអេឡិចត្រូនិក** ៖ legalcouncilmef@gmail.com
- **អាសយដ្ឋាន** ៖ ផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ដូចគ្នានេះដែរ ក្នុងករណីមានភ័ស្តុតាង ឬពិនិត្យឃើញថាអ្នកជាប់ពន្ធ ឬតំណាងអ្នកជាប់ពន្ធមិនគោរពតាមក្រមសីលធម៌ដូចមានចែងក្នុងចំណុចទី២ នៃជំពូក៥ នៃសៀវភៅណែនាំនេះ មន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ក៏អាចប្រើយន្តការរាយការណ៍ ឬប្តឹង ដូចមានចែងខាងលើ ដើម្បីចាត់វិធានការស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ចម្ងល់ផ្សេងៗ និងការពិគ្រោះយោបល់

ករណីលោក-លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាសមានចម្ងល់ផ្សេងៗ សូមទំនាក់ទំនងតាមរយៈ Call Center របស់អគ្គនាយកដ្ឋានពន្ធដារលេខ **១២៧៧** ដោយឥតគិតថ្លៃ ឬផ្ញើសារមកកាន់ GDT Live Chat ឬសារអេឡិចត្រូនិក info@tax.gov.kh។ លោក-លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាសក៏អាចមកធ្វើការទំនាក់ទំនងដោយផ្ទាល់ នៅអគ្គនាយកដ្ឋានពន្ធដារ ដែលមានអាសយដ្ឋានខាងក្រោម៖

**អគារលេខ ៥២២-៥២៤ កែងមហាវិថីសហព័ន្ធរុស្សី (១១០) និងមហាវិថីម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ**

**លេខទំនាក់ទំនង ៖ (៨៥៥) ២៣ ៨៨៦ ៧០៨**

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ......................អពដ

AU2023 **ឧបសម្ព័ន្ធទី១**

ថ្ងៃ ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង
## ស្តីពី
## ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ

**ជម្រាបជូនលោក លោកស្រីនាយកក្រុមហ៊ុន**

ឈ្មោះក្រុមហ៊ុន ៖
ជាអក្សរឡាតាំង ៖
លេខអត្តសញ្ញាណកម្ម ៖ ចុះបញ្ជីនៅ៖
សកម្មភាពអាជីវកម្ម ៖
អាសយដ្ឋាន ៖

អនុលោមតាមបទប្បញ្ញត្តិស្តីពីពន្ធដារ អគ្គនាយកដ្ឋានពន្ធដារសូមចាត់បញ្ជូនមន្ត្រីស៊ើបអង្កេតនៃនាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ ធ្វើការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារលើក្រុមហ៊ុនរបស់លោក លោកស្រី ចំពោះការបំពេញកាតព្វកិច្ចសារពើពន្ធក្នុងឆ្នាំជាប់ពន្ធ ០១-០១-២០១៨ ដល់៣១-១២-២០២០។

អាស្រ័យហេតុនេះ សូមលោក លោកស្រីមេត្តារៀបចំបញ្ជិកាគណនេយ្យ កំណត់ត្រា លិខិតគតិយុត្ត វិក្កយបត្រ សក្ខីបត្រ ឯកសារផ្សេងៗ ឱ្យបានត្រឹមត្រូវ និងពេញលេញសម្រាប់បង្ហាញនិងផ្តល់ជូនមន្ត្រីស៊ើបអង្កេត។

លោក លោកស្រីអាចជ្រើសរើសទីប្រឹក្សា ដើម្បីជួយបញ្ជាក់បំភ្លឺអំពីបញ្ហាទាំងឡាយទាក់ទិននឹងការស៊ើបអង្កេតនេះ។

កាតព្វកិច្ចរបស់អ្នកជាប់ពន្ធ និងអំណាចរបស់រដ្ឋបាលសារពើពន្ធមាននៅក្នុងឧបសម្ព័ន្ធជូនភ្ជាប់មកជាមួយ។

សូមលោក លោកស្រីនាយកក្រុមហ៊ុន ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ

P712

**អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**មន្ត្រីស៊ើបអង្កេត៖**
១. ២. ៣......

**ហត្ថលេខា និងត្រា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
*លេខ.........................អពដ*

AU2023

**ឧបសម្ព័ន្ធទី២**

ថ្ងៃ ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៣

## លិខិតបញ្ជាបេសកកម្ម

**យោង ៖** - មាត្រា ១៩៤ និងមាត្រា ២៣០ នៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣និងបទប្បញ្ញត្តិស្តីពីពន្ធដារពាក់ព័ន្ធ
- លិខិតប្រគល់សិទ្ធិលេខ០៥៣ សហវ ចុះថ្ងៃទី០៤ ខែធ្នូឆ្នាំ២០១៣ របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

សូមឧទ្ទេសនាមមន្ត្រីស៊ើបអង្កេតនៃនាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ ដូចមានរាយនាមខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. | លោក | អគ្គលេខពន្ធដារ | អនុប្រធាននាយកដ្ឋាន | ប្រធានប្រតិភូ |
| ២. | លោក | អគ្គលេខពន្ធដារ | អនុប្រធាននាយកដ្ឋាន | អនុប្រធានប្រតិភូ |
| ៣. | លោក | អគ្គលេខពន្ធដារ | ប្រធានការិយាល័យ | អនុប្រធានប្រតិភូ |
| ៤. | លោក | អគ្គលេខពន្ធដារ | អនុប្រធានការិយាល័យ | សមាជិក |
| ៥. | លោក | អគ្គលេខពន្ធដារ | មន្ត្រី | សមាជិក |
| ៦. | លោក | អគ្គលេខពន្ធដារ | មន្ត្រី | សមាជិក |

ធ្វើដំណើរទៅកាន់ ៖ ក្រុមហ៊ុន
ជាឡាតាំង៖
លេខអ.ត.ប៖
អាសយដ្ឋាន៖
មានភារកិច្ច ៖ ស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ
ឆ្នាំជាប់ពន្ធ ៖ ០១-០១-២០១៨ ដល់ ៣១-១២-២០២០
កាលបរិច្ឆេទចេញដំណើរ ៖ ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៣
កាលបរិច្ឆេទត្រឡប់ ៖ រហូតដល់ថ្ងៃបញ្ចប់បេសកកម្ម
មធ្យោបាយធ្វើដំណើរ ៖ រថយន្ត

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលមានសមត្ថកិច្ចពាក់ព័ន្ធ មេត្តាជួយសម្រួលដល់បេសកកម្មនេះឱ្យសម្រេចដោយជោគជ័យ។

**អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

P71

**ហត្ថលេខា និងត្រា**

**ចម្លងជូន ៖**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី កសហវ
- នាយកដ្ឋានបុគ្គលិក នៃអគ្គលេខាធិការដ្ឋាន កសហវ
  *"ដើម្បីជូនជ្រាប"*
- រដ្ឋបាលរាជធានី/ខេត្ត
- សាខាពន្ធដារខេត្ត-ខណ្ឌ
  *"ដើម្បីជូនជ្រាប និងសហការអនុវត្ត"*
- សាមីខ្លួន
  *"ដើម្បីអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ

អគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៨៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (+855) 23 886 708 / ទូរសារ: (+855) 23 886 700, E-mail: gdt@tax.gov.kh, Website: www.tax.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
*លេខ......................អពជ*

**ឧបសម្ព័ន្ធទី៣**

L2023010: 96TD2869

*លេខសំណុំរឿង*
*ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២*

ថ្ងៃចន្ទ ៣រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០២៣

# លិខិតកោះហៅ (ដើមលិខិត)

យើងជាមន្ត្រីនគរបាលយុត្តិធម៌

យោង៖ - មាត្រា៩៤ មាត្រា១១១ មាត្រា១១២ និងមាត្រា១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
- ការអនុញ្ញាតឱ្យបើកការស៊ើបអង្កេតបឋមរបស់ព្រះរាជអាជ្ញា ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០២៣ លើសំណុំរឿង៖ បទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដាររបស់សហគ្រាស

## កោះហៅ

- ឈ្មោះ :
- លិខិតឆ្លងដែន :
- ជនជាតិ :
- ថ្ងៃ ខែ ឆ្នាំកំណើត :
- ទីកន្លែងកំណើត :
- ទីលំនៅបច្ចុប្បន្ន :
- មុខរបរ :
- លេខទូរស័ព្ទ :

**ឱ្យចូលមកកាន់** ៖ នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ បន្ទប់លេខ ....
អគារលេខ 92R ផ្លូវសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
**កាលបរិច្ឆេទ** ៖ នៅថ្ងៃទី ........ ខែ ............ ឆ្នាំ .......... វេលាម៉ោង .................... ព្រឹក/រសៀល
**ដើម្បី** ៖ ផ្តល់ចម្លើយពាក់ព័ន្ធនឹងប្រតិបត្តិការអាជីវកម្ម និងប្រតិបត្តិការធនាគាររបស់ សហគ្រាស

**មន្ត្រីទំនាក់ទំនង ៖** ទូរស័ព្ទលេខ :

សាមីខ្លួនត្រូវអញ្ជើញមកតាមលិខិតកោះហៅនេះឲ្យទាន់ពេលវេលា និងយកមកជាមួយនូវ**<u>ឯកសារពាក់ព័ន្ធនឹងករណីខាងលើ</u>** ប្រសិនបើមាន។

បានប្រគល់លិខិតកោះហៅនេះឱ្យឈ្មោះ: ..........................................
នៅ.................................យុំ/សង្កាត់.............................
ស្រុក/ខណ្ឌ ...................... ខេត្ត/រាជធានី ...........................
ម៉ោង............នៅថ្ងៃទី..........ខែ............ឆ្នាំ..............ផ្តល់រួចហើយ

លិខិតកោះហៅនេះ ធ្វើជាពីរច្បាប់ ដោយបានទុកមួយច្បាប់ឱ្យសាមីខ្លួន។

**អ្នកប្រគល់** **អ្នកទទួល**
**ហត្ថលេខា ឬស្នាមមេដៃ**

**មន្ត្រីនគរបាលយុត្តិធម៌**
**ជ. អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**ហត្ថលេខា និងត្រា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

លេខ.........................អពដ

AU2023

**ឧបសម្ព័ន្ធទី៤**

ថ្ងៃ ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៣

## លិខិតជូនដំណឹង
## ស្តីពីលទ្ធផលនៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ

**ជម្រាបជូនលោក លោកស្រីនាយកក្រុមហ៊ុន**

ឈ្មោះក្រុមហ៊ុន ៖
ជាអក្សរឡាតាំង ៖
លេខអត្តសញ្ញាណកម្ម ៖ ចុះបញ្ជីនៅ៖
សកម្មភាពអាជីវកម្ម ៖
អាសយដ្ឋាន ៖

ខ្ញុំសូមជម្រាបជូន លោក លោកស្រីថាក្រុមហ៊ុនរបស់លោក លោកស្រីត្រូវបាន**ស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ**ចំពោះការបំពេញកាតព្វកិច្ចសារពើពន្ធ ក្នុងការិយបរិច្ឆេទ ថ្ងៃទី១ ខែមករា ឆ្នាំ២០២០ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។

ដោយអនុលោមតាមមាត្រា២០៩ មាត្រា២១០ និងមាត្រា២១២ នៃច្បាប់ស្តីពីសារពើពន្ធ នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ សូមធ្វើការកែប្រែទិន្នន័យដែលជាមូលដ្ឋានសម្រាប់គណនាប្រាក់ពន្ធ-អាករនិងតម្រូវឱ្យលោក លោកស្រីបង់បន្ថែមនូវប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់ដូចខាងក្រោម៖

| ការិយបរិច្ឆេទ | ប្រាក់ពន្ធ | ពន្ធបន្ថែម | ការប្រាក់ | សរុប |
|---|---|---|---|---|
| 2020 | | | | |

**ព័ត៌មានលម្អិតស្តីពីប្រភេទពន្ធនិងទឹកប្រាក់ពន្ធ/INFORMATION OF TAX TYPES AND AMOUNT DETAIL**

| ល.រ | ខែឆ្នាំ | ប្រភេទពន្ធ | ទឹកប្រាក់ពន្ធ | ពន្ធបន្ថែម | ការប្រាក់ | សរុប |
|---|---|---|---|---|---|---|
| ១. | | | | | | |
| ២. | | | | | | |

លោក លោកស្រីមានរយៈពេល **៣០ថ្ងៃ** ក្រោយកាលបរិច្ឆេទនៃការប្រគល់លិខិតជូនដំណឹងនេះ សម្រាប់ឆ្លើយតបមកអគ្គនាយកដ្ឋានពន្ធដារវិញ នូវយោបល់ដែលអាចជាការយល់ព្រមឬជាការបដិសេធចំណែកណាមួយ ឬទាំងស្រុងចំពោះការកំណត់ពន្ធឡើងវិញនេះ ដោយត្រូវ មានភ្ជាប់ជាមួយឯកសារបញ្ជាក់ជាកស្តុតាងផង។ ការមិនបានឆ្លើយតបក្នុងរយៈពេលនេះ ចាត់ទុកថាលោក លោកស្រីបានយល់ព្រមតាមរដ្ឋបាលសារពើពន្ធ។

ក្នុងករណីលោក លោកស្រីមិនបានបង់ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់ដែលបានកំណត់ខាងលើនេះ លោក លោកស្រីអាចនឹងត្រូវ ទទួលរងនូវទោសទណ្ឌដទៃទៀត តាមច្បាប់ជាធរមាន។

សូមលោក លោកស្រីនាយកក្រុមហ៊ុន ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ

**អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

P712

**ហត្ថលេខា និងត្រា**

មន្ត្រីស៊ើបអង្កេត៖
១. ២. ៣......

អគារលេខមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (+855) 23 886 708 / ទូរសារ: (+855) 23 886 700, E-mail: gdt@tax.gov.kh, Website: www.tax.gov.kh

បោះពុម្ពផ្សាយ ឆ្នាំ២០២៤
© រក្សាសិទ្ធិដោយអគ្គនាយកដ្ឋានពន្ធដារ